អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
នាយកដ្ឋានប្រែប្រួលអាកាសធាតុ

ព្រឹត្តិបត្រព័ត៌មាន

# ការប្រែប្រួល អាកាសធាតុ

# ៦
ខែកក្កដា-កញ្ញា
ឆ្នាំ២០១៦

# គោលនយោបាយប្រែប្រួលអាកាសធាតុ និងការអនុវត្ត

## ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ

ជាផ្នែកមួយនៃការឆ្លើយតបរបស់កម្ពុជា ដើម្បីដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលបានព្យាករ និងដើម្បីបង្កើនសមត្ថភាពបន្សាំនឹងការប្រែប្រួលដែលកំពុងកើតមាន រាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលបានខិតខំចាត់វិធានការដោះស្រាយផលប៉ះពាល់ទាំងនេះនៅថ្នាក់ក្រោមជាតិ ក្នុងគោលបំណងកសាងភាពធន់របស់សហគមន៍នៅទូទាំងប្រទេស។ វិធីសាស្ត្រសំខាន់មានពីរជំហានគឺ ១) ការរៀបចំ និងអនុវត្តន៍វិធានការបន្សាំដោយរដ្ឋាភិបាលឬដោយអង្គការមិនមែនរដ្ឋាភិបាល ដែលភាគច្រើនតាមរយៈគម្រោងគាំទ្រដោយគូអភិវឌ្ឍន៍ និង ២) អភិវឌ្ឍន៍សមត្ថភាពឃុំ និងរដ្ឋបាលមូលដ្ឋានដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការធ្វើផែនការ និងថវិកាឃុំ តាមរយៈការងារដែលដឹកនាំដោយលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប.) និងការគាំទ្រពីនាយកដ្ឋានប្រែប្រួលអាកាសធាតុ (ន.ប.អ.) នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

ដោយទទួលស្គាល់សារសំខាន់នៃការអភិវឌ្ឍសមត្ថភាពបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការធ្វើផែនការ និងថវិកាថ្នាក់ក្រោមជាតិ និងតម្រូវការជម្រុញនិងបង្កើនកិច្ចខិតខំប្រឹងប្រែងនេះ ន.ប.អ.ដោយមានការគាំទ្រពី

បន្តទៅទំព័រទី២

# កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ

## កម្ពុជាត្រៀមផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ



*ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងសហការីចូលរួមកិច្ចប្រជុំបំភ្លឺអំពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសជាមួយគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាននៃរដ្ឋសភា ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦*

អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ បានសម្រេចកិច្ចព្រមព្រៀងសំខាន់មួយក្នុងចំណោមកិច្ចព្រមព្រៀងដទៃទៀត ក្នុងរយៈពេលជាង២០ឆ្នាំនៃកិច្ចចរចាជាសាកលនៅក្នុងសន្និសីទបណ្តាភាគីលើកទី២១ នៅទីក្រុងប៉ារីសកាលពីឆ្នាំ២០១៥ គឺ កិច្ចព្រមព្រៀងទីក្រុងប៉ារីស។ គោលបំណងនៃកិច្ចព្រមព្រៀងនេះគឺដើម្បី ១) ទប់ស្កាត់កំណើនកម្តៅភពផែនដីក្នុងសតវត្សរ៍នេះឱ្យនៅក្រោម២អង្សាសេធៀបនឹងកម្រិតមុនបដិវត្តន៍ឧស្សាហកម្ម និងជំរុញកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយសីតុណ្ហភាពមិនឱ្យកើនលើស១,៥អង្សាសេ, ២) ពង្រឹងលទ្ធភាពរបស់ប្រទេសនីមួយៗក្នុងការដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ សន្និសីទលើកទី២១នេះ បានជំរុញឱ្យមេដឹកនាំពិភពលោកផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងបានឆាប់តាមដែលអាចធ្វើបាន ទើបកិច្ចព្រមព្រៀងនេះអាចចូលជាធរមានមុនឆ្នាំ២០២០។ នៅថ្ងៃទី៥ ខែតុលា ឆ្នាំ

បន្តទៅទំព័រទី៣

## មាតិកាព័ត៌មាន

**គោលនយោបាយប្រែប្រួលអាកាសធាតុ និងការអនុវត្ត**
- ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ.......... ១
- ហិរញ្ញវត្ថុអាកាសធាតុ : កៀរគរមូលនិធិសម្រាប់គម្រោងអាទិភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ.. ៣
- ការប្រើប្រាស់បច្ចេកស័ព្ទប្រែប្រួលអាកាសតុ.......... ៤

**កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ**
- កម្ពុជាត្រៀមផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ...... ១

**សម្លេងពីមូលដ្ឋាន** .......... ៤

**ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ** .......... ៤

## ចំណាប់អារម្មណ៍របស់និពន្ធនាយក

*សូមគោរពប្រិយមិត្តអ្នកអាន យើងខ្ញុំសូមស្វាគមន៍ចំពោះការអានព្រឹត្តិបត្រព័ត៌មានការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៦។ ព្រឹត្តិបត្រព័ត៌មាននេះនឹងចេញផ្សាយរៀងរាល់ត្រីមាស ដើម្បីឆ្លុះបញ្ចាំងពីការអភិវឌ្ឍគោលនយោបាយអាកាសធាតុថ្មីៗនៅកម្ពុជា ព្រមទាំងបច្ចុប្បន្នភាពការងារជាច្រើនដែលអនុវត្តក្រោមអាណត្តិនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ដោយឡែកក្នុងត្រីមាសទី២និងទី៤ យើងខ្ញុំនឹងបន្ថែមការចែករំលែកបទពិសោធន៍ការងារសំខាន់ៗដែលអនុវត្តដោយអង្គការដៃគូ និងសហគមន៍នានាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋាន។ យើងខ្ញុំសង្ឃឹមថាប្រិយមិត្តអ្នកអាន នឹងចូលរួមជាមួយពួកយើងជាលក្ខណៈអចិន្ត្រៃយ៍ ឬមិនអចិន្ត្រៃយ៍ ក្នុងការពាំនាំសម្លេងពីមូលដ្ឋាន ដែលជាធាតុចូលចាំបាច់នាំឱ្យព្រឹត្តិបត្រនេះជោគជ័យ ក្នុងនាមជាប្រតិបត្តិករការងារប្រែប្រួលអាកាសធាតុ។*

## ក្រុមការងាររៀបចំនិងត្រួតពិនិត្យ

ព្រឹត្តិបត្រព័ត៌មាននេះ ត្រូវបានរៀបចំ កែសម្រួល និងផលិតដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានជំនួយបច្ចេកទេសពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។

# គោលនយោបាយប្រែប្រួលអាកាសធាតុ និងការអនុវត្ត

## ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់...

*បន្តពីទំព័រទី១*

កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា(CCCA) កំពុងប្រើប្រាស់វិធីសាស្ត្រស្រដៀងនឹងគ.ជ.អ.ប. តាមរយៈការជម្រុញតួនាទីរបស់មន្ទីរបរិស្ថានខេត្ត ដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការវិនិយោគឃុំ (ផ.វ.ឃ.) ស្របនឹងគោលនយោបាយផ្ទេរមុខងារពីថ្នាក់ជាតិទៅកាន់ថ្នាក់ក្រោមជាតិ។ ដ្យាក្រាមខាងក្រោមបង្ហាញពីវិធីសាស្ត្រដែលន.ប.អ.និងកម្មវិធីCCCAប្រើប្រាស់ ដែលក្នុងនោះមន្ទីរបរិស្ថានខេត្តបានចូលរួមក្នុងដំណើរការទាំងមូលចាប់ពីការបញ្ជ្រាបបឋមរហូតដល់ការសាកល្បងគម្រោងប្រែប្រួលអាកាសធាតុខ្នាតតូច ក្រោមការគាំទ្របច្ចេកទេសពីកម្មវិធីCCCA។ មន្ទីរបរិស្ថានខេត្តនិងឃុំដែលបានជ្រើសរើស បានទទួលវគ្គបណ្ដុះបណ្ដាលស្ដីពីការប្រែប្រួលអាកាសធាតុ រួមបញ្ចូលទាំងការកំណត់ និងការបង្កើតវិធានការឆ្លើយតបមុននឹងធ្វើការបញ្ជ្រាបនិងចាប់ផ្ដើមសាកល្បងគម្រោងនោះ។




*ដ្យាក្រាមបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការវិនិយោគឃុំ*

ន.ប.អ. និងកម្មវិធីCCCA បានគាំទ្រមន្ទីរបរិស្ថានខេត្តចំនួន៦ក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការវិនិយោគឃុំ ដែលនៅឆ្នាំ២០១៥មាន ខេត្តកំពង់ចាម កំពត និងពោធិ៍សាត់ និងឆ្នាំ២០១៦មានខេត្តឧត្តរមានជ័យ ត្បូងឃ្មុំ និងតាកែវ សរុបចំនួន១៩ឃុំ។ មន្ទីរបរិស្ថានខេត្តបានធ្វើការយ៉ាងជិតស្និតជាមួយឃុំក្នុងការរៀបចំផ.វ.ឃ. ដោយបញ្ចូលសំណើគម្រោងអាទិភាពផ្ដោតលើវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុចំនួនពី៧ទៅ១៥គម្រោងសម្រាប់ឃុំនីមួយៗ។ ក្រៅពីនេះ កម្មវិធីCCCA ក៏បានផ្ដល់មូលនិធិដល់គម្រោងប្រែប្រួលអាកាសធាតុអាទិភាព ចំនួន២ ដែលត្រូវបានជ្រើសរើសតាមរយៈដំណើរការធ្វើផែនការដោយឃុំ និងមិនបានទទួលមូលនិធិឃុំ។ បច្ចុប្បន្ន គម្រោងទាំង២បានកំពុងអនុវត្តគឺ ការសាងសង់ទ្វារទឹកការពារទឹកប្រៃហូរចូលទឹកសាបនៅតំបន់ឆ្នេរក្នុងខេត្តកំពត និងការស្ដារទ្វារទឹកក្នុងប្រព័ន្ធធារាសាស្ត្រដែលខូចខាតក្នុងខេត្តពោធិ៍សាត់ ដើម្បីស្តុកទឹកសម្រាប់ប្រព័ន្ធស្រោចស្រពស្រែនៅតំបន់ទន្លេសាប ដែលក្នុង១គម្រោងទទួលបានថវិកា ៥០០០ដុល្លារអាមេរិក។

កម្មវិធីCCCA ឃើញថា មន្ទីរបរិស្ថានខេត្ត និងឃុំមានឆន្ទៈចូលរួមចំណែកដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុក្នុងតំបន់របស់ពួកគេ ហើយអាជ្ញាធរថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងថ្នាក់ឃុំ បានជួបប្រទះបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងសមត្ថភាពកំណត់ជម្រើសបន្សាំសមស្របដែលទាមទារឱ្យមានជំនួយបន្ថែមផ្នែកបច្ចេកទេសពីអ្នកជំនាញការប្រែប្រួលអាកាសធាតុ។ ទោះបីជាឃុំនីមួយៗមានសិទ្ធិក្នុងការទទួលមូលនិធិឃុំ/សង្កាត់ ប៉ុន្តែឱកាសសម្រាប់អនុវត្តគម្រោងប្រែប្រួលអាកាសធាតុនៅថ្នាក់ឃុំ គឺនៅតែពឹងផ្អែកយ៉ាងខ្លាំងលើមូលនិធិពីអង្គការមិនមែនរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ។ កិច្ចខិតខំប្រឹងប្រែងរបស់គ.ជ.អ.ប. និង ន.ប.អ. ក្នុងការពង្រីកវិសាលភាពគម្រោងបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការធ្វើផែនការ និងរៀបចំថវិកាថ្នាក់ក្រោមជាតិ ទាមទារឱ្យមានការគាំទ្រពេញទំហឹងតាម រយៈការផ្សព្វផ្សាយវិធីសាស្ត្របច្ចុប្បន្នទៅកាន់ភាគីពាក់ព័ន្ធគ្រប់វិស័យ សំដៅជម្រុញឱ្យមានការចូលរួម និងបង្កើនការគាំទ្រ។



*ក្រុមប្រឹក្សាឃុំបង្ហាញពីតម្លៃនៃគម្រោងសាងសង់ដែលទាក់ទងនឹងអាកាសធាតុ ដែលស្នើឡើងដោយអ្នកដេញថ្លៃក្នុងតំបន់ ខែកក្កដា ឆ្នាំ២០១៦ នៅខេត្តពោធិ៍សាត់*

## ហិរញ្ញវត្ថុអាកាសធាតុ : គៀគរមូលនិធិសម្រាប់គម្រោងអាទិភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ

កម្មវិធីត្រៀមហិរញ្ញវត្ថុអាកាសធាតុដែលអនុវត្តដោយកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់(GIZ) សហការនិងគាំទ្រហិរញ្ញវត្ថុដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ កំពុងគាំទ្រនាយកដ្ឋានប្រែប្រួលអាកាសធាតុ(ន.ប.អ.)នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍដោយចីរភាព រៀបចំដំណើរការផែនការជាតិបន្សាំសម្រាប់កម្ពុជា(NAP)ដែលផ្តោតសំខាន់ទៅលើយុទ្ធសាស្ត្រហិរញ្ញវត្ថុ និងការអនុវត្តផែនការ។ ជំហានសំខាន់មួយ ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍយុទ្ធសាស្ត្រហិរញ្ញប្បទាន គឺការវាយតម្លៃសក្តានុពលនៃសកម្មភាពអាទិភាពតាមវិស័យដែលមានក្នុងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ(ផ.ស.ប.អ.) ដើម្បីគៀគរហិរញ្ញប្បទានអាកាសធាតុ និងកែលម្អការកំណត់ថ្លៃគម្រោងអាទិភាព។

កម្មវិធីត្រៀមហិរញ្ញវត្ថុអាកាសធាតុ បានគាំទ្រក្រសួងពាក់ព័ន្ធក្នុងការស្វែងយល់អំពីជំហានចាំបាច់ នៃការរៀបចំរចនាសម្ព័ន្ធតម្លៃលម្អិតដែលមាននៅក្នុងផ.ស.ប.អ. របស់ក្រសួងនោះ។ ការគាំទ្រនេះរួមមាន ការបណ្តុះបណ្តាលអំពីទស្សនទាន និងវិធីសាស្ត្រកំណត់ថ្លៃគម្រោងប្រែប្រួលអាកាសធាតុ ហើយគ្រប់សកម្មភាពអាទិភាពនៃផ.ស.ប.អ. ត្រូវបានពិនិត្យនិងកំណត់អាទិភាពដោយផ្អែកលើសក្តានុពល និងការត្រៀមរបស់គម្រោងក្នុងការទទួលមូលនិធិពីមូលនិធិអាកាសធាតុអន្តរជាតិ។

ខណៈដែលផ.ស.ប.អ. ជាច្រើននៅមិនទាន់ទទួលមូលនិធិ ការវាយតម្លៃបានសន្និដ្ឋានថា ផ.ស.ប.អ.ដែលមានស្រាប់ ជាចំណុចចាប់ផ្តើមដ៏ប្រសើរសម្រាប់គៀគរធនធានបន្ថែមដើម្បីអនុវត្ត។ ជាអនុសាសន៍នៅក្នុងទិដ្ឋភាពហិរញ្ញវត្ថុអាកាសធាតុអន្តរជាតិ សកម្មភាពនៃសំណើគម្រោងគួរមានអត្ថប្រយោជន៍ខ្ពស់ដែលអាចបង្ហាញដល់ម្ចាស់ជំនួយ។

លទ្ធផលនិងអនុសាសន៍ផ្សេងៗនៃការវាយតម្លៃ រួមមាន :

- សកម្មភាពនៃផ.ស.ប.អ.ដែលមានស្រាប់ ត្រូវមានជំហានបន្ថែមក្នុងការអភិវឌ្ឍគម្រោង ដើម្បីប្រែក្លាយជាសំណើគម្រោងពេញលេញនិងគ្រប់ជ្រុងជ្រោយ។ សកម្មភាពទាំងនោះក៏តម្រូវឱ្យមានមូលនិធិសម្រាប់រៀបចំគម្រោង និងសមត្ថភាពអភិវឌ្ឍន៍គម្រោងបន្ថែមទៀត។
- អតិក្រមតាមកម្មវិធី និងអន្តរក្រសួង គួរផ្តោតលើកិច្ចខិតខំប្រឹងប្រែងដែលអាចប្រើប្រាស់ចំណេះដឹងរួមគ្នា ដើម្បីធ្វើផែនការ និងអនុវត្តសកម្មភាពប្រែប្រួលអាកាសធាតុ។
- ក្នុងទិដ្ឋភាពនៃការគៀគរមូលនិធិក្នុងស្រុក ការរៀបចំថវិកាតាមកម្មវិធីគឺជាជំហានវិជ្ជមានឆ្ពោះទៅរកដំណើរការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុតាមគោលនយោបាយ និងការធ្វើសមាហរណកម្មសកម្មភាពប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ជាប្រចាំ។
- បន្ថែមពីលើការយកចិត្តទុកដាក់ក្នុងការគៀគរហិរញ្ញវត្ថុ មធ្យោបាយល្អបំផុតសម្រាប់បង្កើនផលវិជ្ជមាន គឺការបង្កើនវិធានការបន្សាំប្រកបដោយប្រសិទ្ធភាព។



*កិច្ចប្រជុំជាមួយក្រសួងអភិវឌ្ឍន៍ជនបទពិភាក្សាអំពីបទពិសោធន៍នៃការកំណត់ថ្លៃចំណាយគម្រោងបន្សាំ និងស្ថានភាពនៃការអនុវត្តផ.ស.ប.អ. ខែកក្កដា ឆ្នាំ២០១៦*

# កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ

## កម្ពុជាត្រៀមផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស...

*បន្តពីទំព័រទី១*

២០១៦ កិច្ចព្រមព្រៀងទីក្រុងប៉ារីស បានឈានដល់ចំណុចរបត់នៃការចូលជាធរមាន ហើយការចូលជាធរមានផ្លូវការគឺនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅពេលដែលព្រឹត្តិបត្រព័ត៌មានប្រែប្រួលអាកាសធាតុលេខនេះត្រូវបានបោះពុម្ពផ្សាយ។

រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាទទួលយកកិច្ចព្រមព្រៀងទីក្រុងប៉ារីសកាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ នៅទីស្នាក់ការកណ្តាលអង្គការសហប្រជាជាតិ ទីក្រុងញូវយ៉ក ហើយកំពុងរៀបចំដំណើរការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងនេះ។ នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលជាស្ថាប័នបង្គោលនៃអនុសញ្ញា កំពុងសម្របសម្រួលជាមួយរដ្ឋាភិបាលលើដំណើរការទាំងមូលនៃការផ្តល់សច្ចាប័ន។ កិច្ចព្រមព្រៀងនេះ ត្រូវបានបកប្រែជាភាសាខ្មែរដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុ និងទទួលការត្រួតពិនិត្យដោយទីស្តីការគណៈរដ្ឋមន្ត្រី មុនបញ្ជូនទៅកាន់រដ្ឋសភា។ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងសហការីបានចូលបំភ្លឺសេចក្តីព្រាងច្បាប់នេះនៅក្នុងកិច្ចប្រជុំជាមួយគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន មុននឹងដាក់ជូនកិច្ចប្រជុំពេញអង្គនៃរដ្ឋសភា។ ក្រោយពីទទួលបានការអនុម័តពីរដ្ឋសភា កិច្ចព្រមព្រៀងនឹងត្រូវលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំពេញអង្គនៃព្រឹទ្ធសភា ដើម្បីដាក់ថ្វាយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះព្រះហស្តលេខា មុននឹងដាក់តម្កល់នៅអង្គការសហប្រជាជាតិ។



*កិច្ចប្រជុំរវាងតំណាងក្រសួងបរិស្ថាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាននៃរដ្ឋសភា ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦*

អត្ថប្រយោជន៍សំខាន់ៗដែលកម្ពុជារំពឹងថានឹងទទួលបានពីការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស រួមមាន :

- ការទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ ការចែករំលែកបច្ចេកវិទ្យា និងការកសាងសមត្ថភាពដែលអាចឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។
- ការចូលរួមនៅក្នុងយន្តការកំណត់តម្លៃកាបូនថ្មី។
- ការកាត់បន្ថយថ្លៃចំណាយរបស់ប្រទេសលើការងារបន្សាំរយៈពេលវែង។

ទោះបីជាប្រទេសកម្ពុជាត្រូវបំពេញកាតព្វកិច្ចដាក់លាក់ដែលកំណត់ក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ប៉ុន្តែកិច្ចព្រមព្រៀងនេះបានផ្តល់ភាពបត់បែនសម្រាប់ប្រទេសកំពុងអភិវឌ្ឍ ដោយផ្អែកលើគោលការណ៍ទទួលខុសត្រូវរួម តែក្នុងកម្រិតផ្សេងគ្នា ក៏ដូចជាទៅតាមកាលៈទេសៈប្រទេស។

## ការប្រើប្រាស់បច្ចេកសព្ទប្រែប្រួលអាកាសធាតុ

ដើម្បីជានាសង្គតិភាព និងភាពត្រឹមត្រូវក្នុងការប្រើប្រាស់បច្ចេកសព្ទប្រែប្រួលអាកាសធាតុ នាយកដ្ឋានប្រែប្រួលអាកាសធាតុ ដោយមានការគាំទ្រពីកម្មវិធីសម្ព័ន្ធប្រែប្រួលអាកាសធាតុកម្ពុជា(CCCA) និងកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ(SPCR) បានចងក្រងសទ្ទានុក្រមការប្រែប្រួលអាកាសធាតុជាខេមរភាសា។ ជាជំហានចុងក្រោយក្នុងការធានាបាននូវស្តង់ដាគុណភាពខ្ពស់ ឯកសារនេះត្រូវបានស្នើសុំការត្រួតពិនិត្យទៅកាន់ប្រឹក្សាជាតិភាសាខ្មែរ នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៦ ដើម្បីធ្វើការពិនិត្យឡើងវិញយ៉ាងហ្មត់ចត់ ផ្ទៀងផ្ទាត់អត្ថន័យ និងអក្ខរាវិរុទ្ធនៃពាក្យនីមួយៗស្របតាមក្បួនភាសាខ្មែរ។

ក្រុមការងារសទ្ទានុក្រមប្រែប្រួលអាកាសធាតុដែលដឹកនាំដោយឯកឧត្តម ច័ន្ទ សំណព្វ ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ រួមជាមួយ សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ មន្ត្រីជំនាញនាយកដ្ឋានប្រែប្រួលអាកាសធាតុ អ្នកជំនាញការកម្មវិធីCCCAនិងកម្មវិធីSPCR បានប្រជុំជាទៀងទាត់រៀងរាល់



មន្ត្រីជំនាញប្រែប្រួលអាកាសធាតុ ពន្យល់អំពីខ្លឹមសារបច្ចេកទេសប្រែប្រួលអាកាសធាតុ នៅក្នុងកិច្ចប្រជុំ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ នៅក្រុមប្រឹក្សាជាតិភាសាខ្មែរ

ថ្ងៃអង្គារ៍ និងថ្ងៃពុធ ចាប់តាំងពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ រហូតដល់បច្ចុប្បន្ន ដើម្បីធ្វើការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ពាក្យនីមួយៗយ៉ាងហ្មត់ចត់។

បច្ចេកសព្ទនៅក្នុងសទ្ទានុក្រម បានដកស្រង់ចេញពីសទ្ទានុក្រមផ្លូវការរបស់អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីអំពីការប្រែប្រួលអាកាសធាតុ (UNFCCC) ក្រុមការងារអន្តររដ្ឋាភិបាលប្រែប្រួលអាកាសធាតុ(IPCC) កម្មវិធីបរិស្ថានសហប្រជាជាតិ(UNEP) និងផ្សេងទៀត ដោយផ្តោតលើ :

- វិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុ
- មូលហេតុ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ
- បន្សាំ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់
- ការគ្រប់គ្រងគ្រោះមហន្តរាយ
- យន្តការ និងការឆ្លើយតបថ្នាក់ជាតិ និងអន្តរជាតិ
- ប្រព័ន្ធអេកូឡូស៊ី និងបរិស្ថាន

ដំណើរការត្រួតពិនិត្យ ចាប់ផ្តើមពីខែមីនារហូតបច្ចុប្បន្ន(ចុងខែកញ្ញា ឆ្នាំ២០១៦) ក្រុមការងារបានត្រួតពិនិត្យនិងអនុម័តពាក្យប្រមាណ៣០០ពាក្យ ក្នុងចំណោមពាក្យសរុបប្រមាណ៥០០ពាក្យ។ ការត្រួតពិនិត្យនឹងបញ្ចប់ជាស្ថាពរនៅចុងឆ្នាំ២០១៦ ហើយបោះពុម្ពផ្សាយនៅដើមឆ្នាំ២០១៧។




ឯកឧត្តម ច័ន្ទ សំណព្វ ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ ដឹកនាំកិច្ចប្រជុំត្រួតពិនិត្យបច្ចេកសព្ទការប្រែប្រួលអាកាសធាតុ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ នៅក្រុមប្រឹក្សាជាតិភាសាខ្មែរ

## ការចេញផ្សាយបន្ទាប់

### សម្លេងពីមូលដ្ឋាន



អ្នកភូមិក្នុងតំបន់ការពារសហគមន៍ជប់តាសុខស្ថិតក្នុងដែនឧទ្យានជាតិភ្នំគូលេន កំពុងជួបបញ្ហាប្រឈមលើផលិតកម្មកសិកម្ម ដោយសារភាពលំបាកនៃការទទួលបានទឹកស្រោចស្រព។ គម្រោង "ការលើកកម្ពស់ភាពធន់នឹងការប្រែប្រួលអាកាសធាតុរបស់សហគមន៍ជនបទរស់នៅក្នុងតំបន់ការពារនៃប្រទេសកម្ពុជា" កំពុងសហការជាមួយអ្នកភូមិក្នុងការស្វែងយល់អំពីវិធីសាស្ត្រសមស្របជាងគេ ដើម្បីត្រៀមខ្លួនដោះស្រាយនឹងហានិភ័យដែលកើតឡើងដោយសារការប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ននិងអនាគត។ អ្នកអាននឹងស្វែងយល់បន្ថែមអំពីយុទ្ធសាស្ត្រគាំទ្រ ដើម្បីយកឈ្នះលើបញ្ហាប្រឈមទាំងនេះ និងការផ្លាស់ប្តូរជីវភាពរបស់ពួកគេ នៅក្នុងព្រឹត្តបត្រលេខបន្ទាប់។

✎ សូមចុះឈ្មោះជាអ្នកចូលរួមចំណែកបង្ហាញសម្លេងពីមូលដ្ឋានជាអចិន្ត្រៃយ៍ ឬមិនអចិន្ត្រៃយ៍ ដោយការផ្ញើអត្ថបទ មកសារអេឡិចត្រូនិក: reaksmey.neou@camclimate.org.kh

## ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ

| | |
|---|---|
| ខែវិច្ឆិកា | សិក្ខាសាលាលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុដល់និស្សិតបរិញ្ញាបត្រ និង សាស្ត្រាចារ្យសាកលវិទ្យាល័យបាត់ដំបង និងសាកលវិទ្យាល័យមានជ័យ។ |
| ខែវិច្ឆិកា | វគ្គបណ្តុះបណ្តាលស្តីពីការធ្វើផែនការថវិកាឆ្លើយតបនឹងអាកាសធាតុទៅកាន់មន្ត្រីផែនការនិងហិរញ្ញវត្ថុនៃក្រសួងស្ថាប័នចំនួន៩។ |
| ខែវិច្ឆិកា | សិក្ខាសាលាបណ្តុះបណ្តាលស្តីពី ការអំពីការបង្រួញមាត្រដ្ឋានសម្រាប់ក្រុមការងារក្រសួងពាក់ព័ន្ធនឹងកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ(MAFF, MRD, MOWRAM, MPWT) |
| ខែវិច្ឆិកា | សិក្ខាសាលាចែករំលែកចំណេះដឹងអំពីការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា |
| ខែវិច្ឆិកា | កិច្ចប្រជុំលើកទី១នៃក្រុមការងារបច្ចេកទេសការប្រែប្រួលអាកាសធាតុរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| ខែធ្នូ | កិច្ចប្រជុំពិគ្រោះយោបល់សូចនាករបន្សាំប្រកបដោយប្រសិទ្ធភាព។ |

*សម្រាប់ព័ត៌មានទាក់ទងនឹងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឬឯកសារបោះពុម្ពថ្មីៗ សូមតាមដានគេហទំព័រ www.camclimate.org.kh*

**គាំទ្រដោយ**

កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា
CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Ministry of Environment
Supported by: European Union, UNDP Empowered lives. Resilient nations., SWEDEN

**អាសយដ្ឋានទាក់ទង**

នាយកដ្ឋានប្រែប្រួលអាកាសធាតុ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
ស្ថិតក្នុងក្រសួងបរិស្ថាន អគារមរតកតេជោ ដីឡូត៍លេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ (+៨៥៥-២៣) ៦៣១ ៨៣៧០ | សារអេឡិចត្រូនិក៖ admin@camclimate.org.kh
គេហទំព័រ៖ www.camclimate.org.kh